ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា ឆ្នាំទី១៩ លេខ៤ ខែធ្នូ ឆ្នាំ២០១៥

# ឧបសគ្គរារាំងការលើកកម្ពស់រូបិយវត្ថុក្នុងស្រុក៖ ការសិក្សាប្រៀបធៀបនឹងប្រទេសបូលីវី អេក្វាទ័រ និងប៉េរូ

## សេចក្ដីផ្ដើម

កម្ពុជា ចាប់ផ្ដើមមានដុល្លារូបនីយកម្មនៅដើមទសវត្សរ៍ ១៩៩០ ហើយបច្ចុប្បន្នគេសំគាល់ថាជា សេដ្ឋកិច្ចប្រើប្រាស់ប្រាក់ដុល្លារខ្លាំងបំផុតនៅអាស៊ី (Duma 2011)។ ទោះបីជាមានអត្ថប្រយោជន៍មួយចំនួនដូចជា ការពង្រឹងផ្នែកហិរញ្ញវត្ថុ ការជួយសម្រួលដល់ពាណិជ្ជកម្ម សញ្ញាបង្ហាញសម្រាប់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពរូបិយវត្ថុ (ដូច្នេះមិនសូវចាំបាច់មានគ្រឿងលើកទឹកចិត្ត) ក្ដី ក៏ដុល្លារូបនីយកម្ម បានបង្កបញ្ហាមួយចំនួន ដែលត្រូវមានការយកចិត្តទុកដាក់ផ្នែកគោលនយោបាយ។ ដុល្លារូបនីយកម្ម ធ្វើឲ្យប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុថយចុះ កាត់បន្ថយតួនាទីជាអ្នកផ្ដល់កម្ចីចុងក្រោយបង្អស់ របស់ធនាគារជាតិនៃកម្ពុជា (NBC) និងធ្វើឲ្យការគ្រប់គ្រងនយោបាយរូបិយវត្ថុមានកម្រិត។ ម្យ៉ាងវិញទៀត រូបិយវត្ថុ គឺជានិមិត្តរូបនៃអធិបតេយ្យភាពជាតិ។ ការពឹងផ្អែកលើប្រាក់ដុល្លារ ធ្វើឲ្យកម្ពុជាខាតបង់ចំណូលបានពីការផលិតរូបិយវត្ថុ (seignorage) ហើយអត្ថប្រយោជន៍នេះ បែរជាបានទៅដល់រដ្ឋាភិបាលសហរដ្ឋអាមេរិកឯណោះវិញ (Tal and Dabadie 2007)។ ដុល្លារូបនីយកម្ម មានផ្ដល់ទាំងអត្ថប្រយោជន៍ និងគុណវិបត្តិ ប៉ុន្តែការវិភាគដោយប្រៀបធៀបរវាងផលប្រយោជន៍ និងការខាតបង់ បង្ហាញថា ការខាតបង់វាធំលើសពី ផលប្រយោជន៍ទទួលបាន (Kang 2005; Tal and Dabadie 2007)។

រដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិជាបន្តបន្ទាប់ បានបង្ហាញពីសមត្ថភាពក្នុងការរក្សាលំនឹងអត្រាប្ដូរប្រាក់ ស្ថិរភាពថ្លៃទំនិញ និងកំណើនសេដ្ឋកិច្ច (Menon 2008)។ ប៉ុន្តែ ទោះបីជា NBC បានបោះពុម្ពក្រដាសប្រាក់រៀលជាថ្មី តាំងពីជាងបីទសវត្សរ៍កន្លងមកហើយក្ដី ក៏សាធារណជនមិនទាន់មានទំនុកចិត្តឡើងវិញលើរូបិយវត្ថុក្នុងស្រុកឡើយ ហើយប្រទេសកម្ពុជានៅតែកំពុងប្រឹងតស៊ូជំរុញការប្រើប្រាស់ប្រាក់រៀល ទប់ទល់នឹងរូបិយប័ណ្ណបរទេសផ្សេងៗ។ ស្ថានភាពនេះ បង្ហាញពីចន្លោះខ្វះខាតនៅក្នុងការស្រាវជ្រាវដែលមានស្រាប់។ ការសិក្សាពីមុនៗ ភាគច្រើនបានរំលងចោលសំណួរថា ហេតុអ្វីកម្ពុជាបានបរាជ័យក្នុងការលើកកម្ពស់ប្រាក់រៀល។ អត្ថបទនេះ មានបំណងចូលរួមចំណែកក្នុងការពិភាក្សានេះ ដោយទាញយកបទពិសោធន៍នៅតំបន់អាមេរិកឡាទីន ជាពិសេស នៅប្រទេសបូលីវី អេក្វាទ័រ និងប៉េរូ។ អត្ថបទនេះ ចាប់ផ្ដើមតាមការពិនិត្យត្រួសៗពីប្រវត្តិប្រាក់រៀល តមកទៀតពិនិត្យពីស្ថានភាពបច្ចុប្បន្ន និងកិច្ចប្រឹងប្រែងបំបាត់ដុល្លារូបនីយកម្ម។ បន្ទាប់មក មានការពិភាក្សាពីបទពិសោធន៍នៅប្រទេសបូលីវី អេក្វាទ័រ និងប៉េរូ ដើម្បីជាមេរៀនសម្រាប់កម្ពុជា។

## កត្តាប្រវត្តិសាស្ត្រដែលប៉ះពាល់ដល់ប្រាក់រៀល

***ការបំបាត់ចោលរូបិយវត្ថុជាតិ (១៩៧៥-៧៩)***

បន្ទាប់ពីចូលកាន់អំណាចក្នុងឆ្នាំ១៩៧៥ របបខ្មែរក្រហមបានកំទេចចោលនូវអគារធនាគារជាតិ និងលុបចោលរូបិយវត្ថុ (Prasso 2001)។ ក្រដាសប្រាក់រៀល បានក្លាយជាសន្លឹកក្រដាសធម្មតាគ្មានតម្លៃដែលហើរប៉ើងរប៉ាត់រប៉ាយនៅតាមថ្នល់ គ្មាននរណាម្នាក់ចាប់អារម្មណ៍នោះឡើយ ហើយក៏គ្មានប្រតិបត្តិការហិរញ្ញវត្ថុដែរ។ ប្រព័ន្ធធនាគារ ត្រូវបំផ្លាញចោលទាំងស្រុង។

***ការភ័យខ្លាចបន្ទាប់ពីសង្គ្រាមស៊ីវិល (របបសេដ្ឋកិច្ចផែនការ ១៩៧៩-៨៩ (១៩៧៩-៨៩)***

ដោយសេដ្ឋកិច្ចនៅយ៉ាប់យ៉ឺនខ្លាំង ហើយបទពិសោធន៍សង្គ្រាមស៊ីវិលក៏នៅថ្មីៗ ក្នុងសតិអារម្មណ៍របស់ប្រជាជននោះ ទំនុកចិត្តលើប្រាក់រៀលបានធ្លាក់ចុះដល់សូន្យ។ អង្ករឃើញមានប្រើប្រាស់ជាទូទៅជំនួសឲ្យក្រដាសប្រាក់ ដើម្បីទិញទំនិញផ្សេងៗ ហើយគេប្រើមាសដើម្បីទិញអង្ករ (Prasso 2001)។ នេះជាប្រព័ន្ធដោះដូរទំនិញ នឹងទំនិញ (Barter System)។ ទោះបីជានៅក្នុងរបបសេដ្ឋកិច្ចផែនការ ឬមានការរឹតត្បិតលើការប្រើប្រាស់រូបិយប័ណ្ណបរទេសក្ដី ក៏ប្រជាជនបានប្រើប្រាស់ និងទទួលយកប្រាក់ដុល្លារអាមេរិក និងប្រាក់បាតថៃ យ៉ាងទូលំទូលាយនៅកម្ពុជា ព្រោះយល់ឃើញថា ជាមធ្យោបាយមានសុវត្ថិភាពសម្រាប់រក្សាតម្លៃ (Tal and Dabadie 2007)។

***អស្ថិរភាពសេដ្ឋកិច្ច និងនយោបាយ៖ ឱនភាពថវិកា លំហូរចូលនៃប្រាក់ដុល្លារ និងអតិផរណាដ៏ធ្ងន់ធ្ងរ (ចុងទសវត្សរ៍១៩៨០ ដល់ ដើមទសវត្សរ៍១៩៩០)***

ចំណូលរដ្ឋាភិបាលដែលមានតិចក្នុងទសវត្សរ៍១៩៩០ បានបង្កឱនភាពថវិកាដែលដោះស្រាយមួយភាគធំដោយសាច់ប្រាក់បានពី NBC។ NBC បានបញ្ចេញរូបិយវត្ថុស្មើនឹង ២០% នៃចំណាយសាធារណៈនៅឆ្នាំ១៩៨៩ និងបង្កើនដល់ ៤០% នៅឆ្នាំ១៩៩០ (Irvin 1993)។ បន្ទាប់មក អតិផរណាក៏ចាប់ផ្ដើម ហើយក្លាយជា

---

អត្ថបទនេះ រៀបចំដោយ ឃន ដាលីន កម្មសិក្សាការីផ្នែកសេដ្ឋកិច្ច នៃវិទ្យាស្ថាន CDRI ដោយប្រើប្រាស់ព័ត៌មានបានពីនិក្ខេបបទរបស់ខ្លួនក្នុងឆ្នាំ២០១៥។ សូមយោងអត្ថបទនេះថា៖ Khorn Dalin. 2016. “The Obstacles to Promoting Local Currency: A Cross-Country Study of Bolivia, Ecuador and Peru.” *Cambodia Development Review* 20(1): 13-18.

១ "ផលធៀបរវាងចំណាយលើការផលិត និងចែកចាយរូបិយវត្ថុ ជាមួយនឹងចំណូលទទួលបានពីការផ្គត់ផ្គង់រូបិយវត្ថុនេះឲ្យគេប្រើប្រាស់" (Tal and Dabadie 2007: 12)។

អតិផរណាលោតផ្លោះ មានអត្រាលេខបីខ្ទង់ នៅឆ្នាំ១៩៩២។ ប្រាក់រៀលធ្លាក់ថ្លៃយ៉ាងគំហុកធៀបនឹងប្រាក់ដុល្លារ ពី ៨០០ នៅឆ្នាំ១៩៩០ ដល់ ២៦០០ រៀល/ដុល្លារ នៅខែមីនា ១៩៩២ (Irvin 1993)។ ការបាត់បង់អំណាចទិញ ផុសចេញពីការធ្លាក់ថ្លៃនេះ បានធ្វើឲ្យសាធារណជនបាត់បង់ទំនុកចិត្តលើប្រាក់រៀល។

បន្ទាប់មកទៀត ស្ថានភាពនយោបាយក្នុងស្រុក មានភាពប្រែប្រួលល្អឡើងវិញ ដោយមានការចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសនៅឆ្នាំ១៩៩១ ដែលបានបើកផ្លូវសម្រាប់សេរីភាវូបនីយកម្មផ្នែកនយោបាយ។ អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (UNTAC) ដែលចូលមកប្រទេសកម្ពុជា ដើម្បីត្រួតពិនិត្យលើការបោះឆ្នោតថ្នាក់ជាតិលើកដំបូង បន្ទាប់ពីសង្គ្រាមស៊ីវិលនោះ ជាព្រឹត្តិការណ៍ដ៏សំខាន់បំផុត ព្រោះបាននាំមកនូវ លំហូរចូលដ៏ធំសម្បើមនៃមូលធនពីបរទេសជាលើកទី១ ដែលភាគច្រើនក្នុងទម្រង់ជាប្រាក់ដុល្លារអាមេរិក ហើយក៏ជាប្រតិបត្តិការរក្សាសន្តិភាពនៃ អង្គការសហប្រជាជាតិ

រូបភាព១៖ ប្រាក់បញ្ញើជាប្រាក់រៀល និងរូបិយប័ណ្ណបរទេស និងការផ្គត់ផ្គង់រូបិយវត្ថុ




ប្រភព៖ Beresford et al. 2004, NBC 2005, 2010, 2013, 2014

រូបភាព២៖ ចំណែកនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសនៃការផ្គត់ផ្គង់រូបិយវត្ថុ (FCD/M2)




ប្រភព៖ NBC 2005, 2010, 2013, 2014

ដែលបានចំណាយថវិកាអស់ច្រើនបំផុត រហូតដល់ប្រមាណ ១,៧ ប៊ីលានដុល្លារ (Tal and Dabadie 2007)។

## ស្ថានភាពបច្ចុប្បន្ន និងកិច្ចប្រឹងប្រែងបំបាត់ដុល្លារូបនីយកម្ម

### *សមាសធាតុនៃរូបិយវត្ថុទូទៅ (Broad Money) នៅកម្ពុជា*

ផ្នែកនេះ ពណ៌នាពីទិន្នន័យរបស់ NBC ស្ដីពីការផ្គត់ផ្គង់រូបិយវត្ថុ (M2) ពីឆ្នាំ១៩៩៣ ដល់ ២០១៤។ ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស (FCD) មានច្រើនជាងគេ ដោយកើនពី ៨៤% នៃបញ្ញើសរុបនៅឆ្នាំ១៩៩៣ ដល់ ៩៥% នៅឆ្នាំ២០១៤ រីឯប្រាក់បញ្ញើជាប្រាក់រៀល (RD) បានធ្លាក់ចុះពី ១៦% មកត្រឹម ៥%។ នៅពេលសេដ្ឋកិច្ចកើនឡើង FCD និង RD ក៏កើនឡើងដែរ។ ពីឆ្នាំ១៩៩៣ ដល់ ២០១៤ FCD បានកើនពី ១២១ ប៊ីលានរៀល ដល់ ៣៥.១៦១ប៊ីលានរៀល ហើយ RD កើនពី ២៣ប៊ីលានរៀល ដល់ ១៨០៥ប៊ីលានរៀល (រូបភាព១)។ ប៉ុន្តែ FCD កើនក្នុងអត្រាខ្ពស់ជាង RD ព្រោះតម្រូវការប្រាក់រៀល មានកម្រិតទាបជាងរូបិយប័ណ្ណបរទេស (Beresford et al. 2004)។ ក្នុងពេលដំណាលគ្នានោះ សន្ទស្សន៍ដុល្លារូបនីយកម្ម បានកើនពី ៣៦% ដល់ ៨៣% (រូបភាព២)។ ការគណនានេះ មិនមានគិតបញ្ចូលនូវរូបិយវត្ថុបរទេសកំពុងចរាចរទេ (FCC: Foreign Currency in Circulation outside the banking system) ហើយតួលេខរបស់វាក៏គេមិនដឹងដែរ។

### *មូលហេតុនាំឲ្យដុល្លារូបនីយកម្មបន្តកើតមាន*

មានមូលហេតុចម្បងពីរ នាំឲ្យដុល្លារូបនីយកម្ម នៅតែបន្តទៅមុខ។ មូលហេតុទី១គឺ ភាពងាយស្រួល ក្នុងការប្រើប្រាស់ប្រាក់ដុល្លារអាមេរិក ហើយមូលហេតុទី២ គឺតម្រូវការ និងលំហូរចូលនៃប្រាក់ដុល្លារកើនឡើង។ ការយល់ថា ប្រាក់ដុល្លារឃើញមានការប្រើប្រាស់យ៉ាងទូលំទូលាយជាស្រេច នៅក្នុងសេដ្ឋកិច្ច ធ្វើឲ្យវាក្លាយជាជម្រើសគេចូលចិត្តប្រើ នៅក្នុងប្រតិបត្តិការទូទាត់ផ្សេងៗ។ ថ្លៃទំនិញ និងសេវាភាគច្រើនគេកំណត់ជាដុល្លារ ហើយការទូទាត់ក៏ធ្វើឡើងដោយប្រើប្រាក់ដុល្លារ។ បៀវត្សរ៍ក្នុងវិស័យឯកជនភាគច្រើន តែងផ្ដល់ឲ្យជាដុល្លារ ហើយប្រាក់ឈ្នួលអប្បបរមា ក៏កំណត់ជាដុល្លារ។ លើសពីនេះទៀត បច្ចុប្បន្នមិនទាន់មានការដាក់កំហិត ឬរឹតត្បិតអ្វីលើការប្រើប្រាស់ប្រាក់ដុល្លារទេ។

ផសស នៅកម្ពុជា (គិតតាមថ្លៃបច្ចុប្បន្នជាប្រាក់ដុល្លារ) កើនជិតមួយជាបីពីឆ្នាំ២០០៣ ដល់ ២០១៣ ដោយមានអត្រាកំណើន ផសស ប្រចាំឆ្នាំ ប្រហែល ៧% ពីឆ្នាំ២០១១ ទៅ ២០១៤ (World Bank 2016, 2015)។ សូចនាករសេដ្ឋកិច្ចចម្បងៗប្រាំផ្ដល់នូវភស្ដុតាងនៃកំណើនលំហូរចូលប្រាក់ដុល្លារ។ ចំណូលផ្នែកទេសចរណ៍អន្តរជាតិ ដែលរួមចំណែក២៩,៩%ក្នុង ផសស នៅឆ្នាំ ២០១៤ បានកើនខ្ពស់ជាងមុន ៥,៥៦ដង ពីឆ្នាំ២០០៣ ដល់ ២០១៣។ ក្នុងអំឡុងពេលដដែល វិនិយោគផ្ទាល់ពីបរទេសសុទ្ធ កើនខ្ពស់ជាងមុន ១៦,០២ដង ជំនួយអភិវឌ្ឍន៍ផ្លូវការសុទ្ធ កើន ១,៥៥ដង ហើយប្រាក់ផ្ញើរចរន្តសុទ្ធ កើន ១,៧៧ដង។ លើសពីនេះទៀត ដោយសារឱនភាពពាណិជ្ជកម្មសុទ្ធបានរីកធំ ស្របតាមកំណើនការនាំចូលនោះ តម្រូវការប្រាក់ដុល្លារក៏បានកើនឡើង។ សូចនាករទាំងប្រាំនេះ គេតែងគណនាជាប្រាក់ដុល្លារ ជាជាងប្រាក់រៀល។ ម្យ៉ាងទៀត ពីឆ្នាំ២០១១ ដល់ ២០១៤ ប្រាក់បញ្ញើកើន ៧,៨៨ដង ហើយកម្ចីកើន ៣,១៧ដង (NBC 2014) ដែលបង្ហាញពីការរឹងប៉ឹងឡើងផ្នែកហិរញ្ញវត្ថុ និងសកម្មភាពសេដ្ឋកិច្ចកាន់តែខ្លាំងក្លា។

សរុបមក ប្រាក់ដុល្លារផ្ដល់នូវលទ្ធភាពកាន់តែប្រសើរផ្នែកសេដ្ឋកិច្ច ដូច្នេះហើយក៏មានតម្រូវការច្រើនជាងប្រាក់រៀល។ ប្រការនេះ បានកាត់បន្ថយជាខ្លាំងនូវជម្រើសគោលនយោបាយរូបិយវត្ថុ។ ដោយហេតុថា ក្នុងរូបិយវត្ថុកំពុងចរាចរ មានប្រាក់រៀលតែមួយភាគតូចនោះ ដូច្នេះ NBC មិនអាចធ្វើអន្តរាគមន៍នៅក្នុងទីផ្សារដោយការផ្គត់ផ្គង់រូបិយវត្ថុ (ឬរូបិយវត្ថុទូទៅM2) ដើម្បីបន្ថយផលប៉ះពាល់នៃបញ្ហាហិរញ្ញវត្ថុបានឡើយ។ ហេតុនេះ ត្រូវលើកកម្ពស់ រូបិយវត្ថុក្នុងស្រុកជាចាំបាច់ ដើម្បីសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ជាពិសេសដើម្បីទទួលបានអំណាចផ្នែករូបិយវត្ថុ។

### *ការវិភាគពីការអនុវត្តគោលនយោបាយ*

កន្លងមក មិនទាន់មានគោលនយោបាយស្វាហាប់ណាមួយសម្រាប់លើកកម្ពស់ ប្រាក់រៀលឡើយ ហើយក៏មិនមានការកំណត់ ពេលវេលាជាក់លាក់អ្វី ដើម្បីបំបាត់ដុល្លារូបនីយកម្មឡើយ (McGrath 2015)។ ខាងផ្នែកតម្រូវការ ការទូទាត់វិក្កយបត្រអគ្គិសនីនិងទឹក ពន្ធ និងបៀវត្សរ៍ក្នុងវិស័យសាធារណៈ ត្រូវប្រើប្រាស់ប្រាក់រៀលជាចាំបាច់ (Tal and Dabadie 2007)។ អង្កេតនាពេលថ្មីៗមួយបង្ហាញថា ការទូទាត់បៀវត្សរ៍ជាប្រភពធំជាងគេនៃរូបិយប័ណ្ណបរទេសនៅកម្ពុជា (Khou and Odajima 2015)។

ខាងផ្នែកផ្គត់ផ្គង់វិញ NBC បានរក្សាស្ថិរភាពសេដ្ឋកិច្ចជាពិសេស ស្ថិរភាពថ្លៃទំនិញនិងសេវា និងអត្រាប្តូរប្រាក់។ អតិផរណា គេគ្រប់គ្រងវាបានឲ្យនៅត្រឹម ៤% នៅឆ្នាំ២០១៣ (NBC 2013)។ លើសពីនេះទៀត NBC បានបញ្ចេញក្រដាសប្រាក់ថ្មីៗទៅក្នុងសេដ្ឋកិច្ច ដើម្បីជំនួសក្រដាសប្រាក់ចាស់ៗដែលសឹកខូច ហើយតាមនេះ អាចលើកស្ទួយមោទនភាពប្រជាជនទៅលើប្រាក់រៀល។ គណៈកម្មការមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើងស្របតាមច្បាប់ស្ដីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជនក្នុងឆ្នាំ២០០៧។ នេះជាមធ្យោបាយមួយទៀត ដើម្បីបង្កើនការប្រើប្រាស់ប្រាក់រៀល ព្រោះការកំណត់ថ្លៃធ្វើឡើងជាប្រាក់រៀល ទាំងនៅក្នុងទីផ្សារបឋម និងទីផ្សារបន្ទាប់បន្សំ។ ទោះយ៉ាងណាក្ដី ផ្សារមូលបត្រកម្ពុជា សព្វថ្ងៃមិនទាន់លូតលាស់បានពេញលេញទេ ហើយរដ្ឋាភិបាលក៏មិនទាន់ចេញផ្សាយប័ណ្ណរតនាគារដែរ។ សមិទ្ធផលមួយទៀតគឺ NBC បានបង្កើតទីផ្សារអន្តរធនាគារមួយដែលដំណើរការបានពេញលេញហើយ ដើម្បីជួយគ្រប់គ្រងហានិភ័យនៃសាច់ប្រាក់ងាយស្រួល។ រដ្ឋាភិបាល ក៏ជិតអនុម័តចេញនូវគោលនយោបាយថ្មីៗទៀត ដើម្បីជំរុញប្រាក់រៀល និងបដិដុល្លារូបនីយកម្ម ដូចជា តាមរយៈការជំរុញទីផ្សារហិរញ្ញវត្ថុជាដើម។

## ដុល្លាររូបនីយកម្មនៅប្រទេសបូលីវី អេក្វាទ័រ និងប៉េរូ

### *ហេតុអ្វីជ្រើសរើសប្រទេសទាំងបីនេះសម្រាប់ការសិក្សា?*

ប្រទេសបូលីវី អេក្វាទ័រ និង ប៉េរូ ធ្លាប់មានដុល្លាររូបនីយកម្មកម្រិតខ្ពស់ដូចនៅកម្ពុជាដែរ។ អត្រាជាមធ្យមនៃ FCD ធៀបនឹងប្រាក់បញ្ញើសរុបជាមធ្យម សម្រាប់អំឡុងពេលពីឆ្នាំ១៩៩៥ ដល់ ២០០៤ មានចាប់ពី ៩៤% នៅកម្ពុជា ៩០% នៅបូលីវី ៧៦% នៅអេក្វាទ័រ និង ៦៨% នៅប៉េរូ (Alvarez-Plata and Garcia-Herrero 2007)។ បូលីវី អេក្វាទ័រ និង ប៉េរូ បានអនុវត្តយុទ្ធសាស្ត្រខុសៗគ្នា ក្នុងការឆ្លើយតបទៅនឹងដុល្លាររូបនីយកម្ម។ អេក្វាទ័រ បានប្រែក្លាយប្រទេសខ្លួនជាសេដ្ឋកិច្ចប្រើប្រាស់ប្រាក់ដុល្លារជាផ្លូវការ រីឯ បូលីវី និង ប៉េរូ បានជ្រើសយក បដិដុល្លាររូបនីយកម្ម ជាជម្រើសដំបូង។ បូលីវី និង ប៉េរូ បានតម្រូវឲ្យអនុវត្តគោលនយោបាយនេះជាកាតព្វកិច្ច ប៉ុន្តែវាត្រឹមតែធ្វើឲ្យស្ថានភាពកាន់តែអាក្រក់ឡើង និងកាន់តែជំរុញដុល្លាររូបនីយកម្ម។ យុទ្ធវិធីទី២ របស់ពួកគេ គឺការអភិវឌ្ឍទីផ្សារ ដែលទទួលបានជោគជ័យច្រើនជាងយុទ្ធវិធីមុន។

### *បទពិសោធន៍របស់ប្រទេសទាំងបី៖ មុន និងក្រោយពេលដុល្លាររូបនីយកម្មកើតឡើង*

អេក្វាទ័រ បានប្រើប្រាស់ប្រាក់ដុល្លារជាផ្លូវការនៅឆ្នាំ២០០០ ជាផ្នែកមួយនៃកំណែទម្រង់រចនាសម្ព័ន្ធ ដើម្បីគ្រប់គ្រងអស្ថិរភាពសេដ្ឋកិច្ច និងនយោបាយធ្ងន់ធ្ងរ។ បន្ទាប់ពីក្លាយជា សេដ្ឋកិច្ចប្រើប្រាក់ដុល្លារជាផ្លូវការ អត្រាអតិផរណាបានធ្លាក់ចុះយ៉ាងខ្លាំង ពី ៩៦,០៩% នៅឆ្នាំ២០០០ មក ៣៧,៦៨% នៅឆ្នាំ២០០១ និង ៣,៥៧%នៅឆ្នាំ២០១៤ (World Bank 2016)។នៅចុងទសវត្សរ៍ ១៩៩០ អេក្វាទ័រ បានជួបនឹងការធ្លាក់ចុះអត្រាកំណើន រហូតដល់ -៤,៧៤% នៅឆ្នាំ១៩៩៩។ និន្នាការនេះ បានប្រែប្រួលប្រសើរឡើងវិញជាបណ្ដើរៗចាប់ពីឆ្នាំ២០០០ មក ដោយ ផសស បានកើនរហូតដល់ ៣,៨០% ក្នុងឆ្នាំ២០១៤។ ម្យ៉ាងវិញទៀត ពាណិជ្ជកម្មដែលនៅស្ពឹកទ្រឹងជាខ្លាំង មុនពេលដុល្លាររូបនីយកម្មផ្លូវការនោះ បានកើនអត្រារួមចំណែកនៅក្នុង ផសស។

ស្រដៀងនឹងបទពិសោធន៍របស់អេក្វាទ័រដែរ ដុល្លាររូបនីយកម្មនៅបូលីវី បានកើតមានឡើងជាចម្លើយតបនឹងអតិផរណាលោតផ្លោះ និងអស្ថិរភាពសេដ្ឋកិច្ចនៅទសវត្សរ៍១៩៧០។ ប៉ុន្តែ វិបត្តិជញ្ជីងទូទាត់ និងអត្រាអតិផរណា ៣២,១៣% នៅឆ្នាំ១៩៨១ បាននាំឲ្យមានការដាក់អនុវត្ត គោលនយោបាយបដិដុល្លាររូបនីយកម្មជាកាតព្វកិច្ចក្នុងឆ្នាំ១៩៨២។ ប្រាំឆ្នាំជាប់ៗគ្នានៃកំណើន ផសស អវិជ្ជមាន និងអតិផរណាលោតផ្លោះ បានកើតមានឡើងបន្ទាប់ពីនោះ។ អត្រាអតិផរណាប្រចាំឆ្នាំជាមធ្យម ស្ទុះឡើងយ៉ាងលឿន ដល់ ១២៣,៥៤% ក្នុងឆ្នាំ១៩៨២ ១១.៧៤៩,៦៤% ក្នុងឆ្នាំ១៩៨៥ និង ២៧៣,៣៥% ក្នុងឆ្នាំ១៩៨៦ មុននឹងធ្លាក់ចុះមកក្នុងកម្រិតអាចគ្រប់គ្រងបានវិញ ប្រមាណពី ១៤ ទៅ ២១% នៅអំឡុងឆ្នាំ១៩៨៧-៩២ (World Bank 2016)។ បន្ទាប់ពីនោះមក គោលនយោបាយអភិវឌ្ឍន៍ទីផ្សារ ដែលបានដាក់អនុវត្តនៅឆ្នាំ២០០៦ ក៏ចាប់ផ្ដល់លទ្ធផលជាវិជ្ជមាន។ នៅឆ្នាំ២០១៤ ប្រាក់បញ្ញើជារូបិយវត្ថុបូលីវីយ៉ាណូ របស់បូលីវី ធៀបនឹងប្រាក់បញ្ញើសរុប កើនដល់ ៧៨% ធៀបនឹង ២៣% នៅឆ្នាំ២០០៦ រីឯឥណទានក្នុងស្រុកធៀបនឹងឥណទានសរុប កើនដល់ ៩២% ធៀបនឹង ១៥% នៅឆ្នាំ ២០០៦ (Catacora 2014)។

ការព្យាយាមសម្រេចនូវ លក្ខណៈវិនិច្ឆ័យបី (ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយប្រយ័ត្នប្រយែង និងចីរភាពប្រទេសជាតិក្នុងផ្នែកបំណុល) ហាក់ទទួលបានជោគជ័យក្នុងការធ្វើឲ្យសេដ្ឋកិច្ចបូលីវី មានលំនឹង បន្ទាប់ពីការអនុវត្តបដិដុល្លាររូបនីយកម្ម (Staines 2014)។ គោលនយោបាយនៅអំឡុងទសវត្សរ៍១៩៩០ នាំឲ្យមានអតិផរណាទាបជាងមុន កំណើនថេរនៃ ផសស និង កំណើនពាណិជ្ជកម្ម។ គោលនយោបាយលើកទឹកចិត្ត ដើរតួនាទីសំខាន់ក្នុងការជំរុញប្រាក់បូលីវីយ៉ាណូ ជាចម្បងតាមរយៈ អត្រាខុសគ្នាខ្លាំងនូវប្រាក់បម្រុងកាតព្វកិច្ច ការបង្កើតសំវិធានធនសម្រាប់ទប់ទល់ហានិភ័យលើឥណទាន ការដាក់កម្រិតលើបំណុលជាប្រាក់បរទេសសុទ្ធ និងពន្ធលើប្រតិបត្តិការហិរញ្ញវត្ថុជាប្រាក់បរទេស (Staines 2014)។ តួយ៉ាង ធនាគារកណ្ដាលបូលីវី បានបង្កើនអត្រាប្រាក់បម្រុងកាតព្វកិច្ច ពី ៧,៥% ដល់ ៣០% និងកំណត់អត្រាប្ដូរប្រាក់ (ថ្លៃទិញ និងថ្លៃលក់ អតិបរមា និងអប្បបរមា) សម្រាប់រូបិយប័ណ្ណបរទេស ឲ្យខ្ពស់ជាង សម្រាប់ប្រាក់បូលីវីយ៉ាណូ។ ប្រតិបត្តិការជារូបិយប័ណ្ណបរទេសលើសពី ២០០០ ដុល្លារ ត្រូវជាប់ពន្ធ (MEPF 2013)។ ប្រាក់បៀវត្សរ៍អប្បបរមានៅបូលីវី គេកំណត់វាជារូបិយវត្ថុក្នុងស្រុក គឺខុសពីនៅកម្ពុជា។ បំណុលរដ្ឋាភិបាល គិតជាភាគរយនៃ ផសស ធ្លាក់ចុះពី ៨០,៤% នៅឆ្នាំ២០០៥ មកត្រឹម ៣២,៤% នៅឆ្នាំ២០១៤ ដែលនាំឲ្យបូលីវីជាប់ចំណាត់ថ្នាក់ទី៥ ដោយ Trading Economics (2016)[២]។ លក្ខខណ្ឌទីផ្សារទាំងនេះ អំណោយផលដល់រដ្ឋាភិបាលក្នុងការចេញប័ណ្ណរតនាគារ ជាពិសេស ប័ណ្ណមានទឹកប្រាក់ជារូបិយវត្ថុបូលីវីយ៉ាណូ ដែលបានជួយកាត់បន្ថយ ដុល្លាររូបនីយកម្មផ្នែកឥណទាន (Garcia-Escribano and Sosa 2011)។

ប្រទេសប៉េរូ ក៏ធ្លាប់ជួបនឹងអតិផរណាលោតផ្លោះ និងកំណើនដុល្លាររូបនីយកម្មដែរ នៅពាក់កណ្ដាលទសវត្សរ៍១៩៧០ ដែលកាន់តែធ្ងន់ធ្ងរឡើង រហូតដល់រដ្ឋាភិបាលត្រូវបង្ខំឲ្យប្រជាជនប្ដូររូបិយប័ណ្ណបរទេសដែលខ្លួនមាន ទៅជារូបិយវត្ថុក្នុងស្រុក។ ប៉ុន្តែ វិធានការនេះ ហុចលទ្ធផលផ្ទុយពីគោលបំណង ព្រោះ ដុល្លាររូបនីយកម្ម បន្តកើនឡើង ហើយប្រាក់បញ្ញើជាប្រាក់ដុល្លារកើនដល់ ៨០% នៃបញ្ញើសរុបនៅឆ្នាំ១៩៩០ ធៀបនឹងជាង ៦០%

---

២ ការកំណត់គុណសម្បត្តិផ្នែកបំណុល ដែលរាយការណ៍ឡើងដោយ សេវាកំណត់គុណសម្បត្តិចម្បងៗប្រាំ គឺ Moody's, Standard & Poor's, Fitch, Economic Indicators, និង Financial Markets បែងចែកចំណាត់ថ្នាក់ទាំង១០ នៅក្នុង Trading Economics (2016) ដូចតទៅ៖ ទី១ ចំណាត់ថ្នាក់កំពូល ទី២ ចំណាត់ថ្នាក់ខ្ពស់ ទី៣ ចំណាត់ថ្នាក់មធ្យមកម្រិតខ្ពស់ ទី៤ ចំណាត់ថ្នាក់មធ្យមកម្រិតទាប ទី៥ ចំណាត់ថ្នាក់មានការឆក់ឱកាសកេញចំណេញមិនគួរវិនិយោគ ទី៦ ចំណាត់ថ្នាក់មានការឆក់ឱកាសកេញចំណេញខ្លាំង ទី៧ ចំណាត់ថ្នាក់មានហានិភ័យខ្ពស់ ទី៨ ចំណាត់ថ្នាក់មានការឆក់ឱកាសកេញចំណេញខ្លាំងបំផុត ទី៩ ចំណាត់ថ្នាក់មិនអាចសងបំណុលដោយមានការប្រមើលឃើញពីលទ្ធភាពតិចតួចក្នុងការរើបឡើងវិញ និង ទី១០ ចំណាត់ថ្នាក់មិនអាចសងបំណុល។

បន្តិច នៅទសវត្សរ៍១៩៨០ (Staines 2014)។ គោលនយោបាយអភិវឌ្ឍន៍ទីផ្សារ ដើរតួនាទីសំខាន់បំផុតក្នុងការជួយសម្រួលបដិដុល្លារូបនីយកម្មនៅប្រទេសប៉េរូ។ ដំបូង វាជួយទប់កំណើនអតិផរណា ដោយធ្វើឲ្យអតិផរណាថយចុះជាងពាក់កណ្ដាល ពី ១៦៣,៤០% នៅឆ្នាំ១៩៨៥ មកត្រឹម ៧៧,៩២% នៅឆ្នាំ១៩៨៦ ប៉ុន្តែ នៅឆ្នាំក្រោយៗនោះទៀត អតិផរណាបានស្ទុះឡើងវិញ រហូតដល់កម្រិតកំពូល ៧៤៨១,៦៦% នៅឆ្នាំ១៩៩០ (World Bank 2016)។ គោលនយោបាយជាច្រើន ដែលបានដាក់អនុវត្តនៅដើមទសវត្សរ៍ ២០០០ បានធ្វើឲ្យប្រាក់បញ្ញើជាប្រាក់ដុល្លារ ធ្លាក់ចុះមកត្រឹម ៥២% ហើយដុល្លារូបនីយកម្មឥណទានធ្លាក់មកត្រឹម ៥៥% នៅឆ្នាំ២០០៩ ធៀបនឹងជិត ៨០% ដូចគ្នានៅឆ្នាំ២០០១។

នៅទសវត្សរ៍២០០០ ម៉ាក្រូសេដ្ឋកិច្ចនៅប៉េរូ គេប្រមើលឃើញល្អ ដោយសារអតិផរណាបានថយចុះ ហើយ ផសស មានកំណើនវិជ្ជមាន។ បំណុលរដ្ឋាភិបាល គិតជាចំណែកនៃ ផសស បានថយចុះ ធ្វើឲ្យប៉េរូឡើងដល់ចំណាត់ថ្នាក់ទី៤ នៅក្នុង Trading Economics (2016) និងបានចេញផ្សាយប័ណ្ណរតនាគារមានទឹកប្រាក់ជារូបិយវត្ថុក្នុងស្រុក។ គោលនយោបាយប្រយ័ត្នប្រយែងបានអនុម័តប្រើ រួមមាន អត្រាខុសគ្នាខ្លាំងនូវប្រាក់បម្រុងកាតព្វកិច្ច ការបង្កើតសំវិធានធន សម្រាប់ទប់ទល់ហានិភ័យលើឥណទាន និង ការដាក់កម្រិតលើបំណុលជាប្រាក់បរទេសសុទ្ធ។ មានគម្លាតគ្នាយ៉ាងធំរវាង អត្រាប្រាក់បម្រុងកាតព្វកិច្ច សម្រាប់ប្រាក់សុលប៉េរូ (តិចជាង ៥%) នឹងរូបិយប័ណ្ណបរទេស (ជាង ៣០%) (Garcia-Escribano 2010) ហើយសំវិធានធន សម្រាប់ទប់ទល់ហានិភ័យលើឥណទាន ជារូបិយប័ណ្ណបរទេស (២០%) ត្រូវបានកំណត់ខ្ពស់ជាង សំវិធានធន លើឥណទានជារូបិយវត្ថុក្នុងស្រុក (៨%)។ ធនាគារកណ្ដាលរបស់ប៉េរូ រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដោយការសន្សំបង្គរទុនបម្រុងអន្តរជាតិ (Sossini, Quispe and Serrano 2013)។ ដូចគ្នានឹងនៅ ប្រទេសបូលីវីដែរ ប្រាក់បៀវត្សរ៍អប្បបរមានៅ ប្រទេសប៉េរូ ត្រូវបានកំណត់ជារូបិយវត្ថុក្នុងស្រុក។

## *ភាពស្រដៀងគ្នា ភាពខុសគ្នា និងគោលនយោបាយ*

នៅបូលីវី កម្ពុជា អេក្វាទ័រ និងប៉េរូ ដុល្លារូបនីយកម្មជាការឆ្លើយតបទៅនឹងអស្ថិរភាពសេដ្ឋកិច្ច និងនយោបាយ ជាពិសេសអតិផរណាលោតផ្លោះ។ ករណីនៅកម្ពុជា ខុសប្លែកពីប្រទេសឯទៀតទាំងអស់ ព្រោះរូបិយវត្ថុក្នុងស្រុក ត្រូវបានបោះបង់ចោលស្ទើរតែទាំងស្រុង (១៩៧៥-៧៩) ហើយបន្តិចក្រោយមកសេដ្ឋកិច្ចកម្ពុជាមានប្រាក់ដុល្លារអាមេរិកច្រើនសន្ធឹកសន្ធាប់ ហូរចូលណែនណាន់តាន់តាប់ភ្លាមៗ រហូតដល់ស្មើនឹង ពីរភាគបី នៃ ផសស នៅឆ្នាំ១៩៩៣ (Khou and Ken 2015)។

មេរៀនពីប្រទេសអេក្វាទ័រ បង្ហាញថា កម្ពុជាមិនគួរជ្រើសរើសដំណោះស្រាយ ពោលគឺ ដុល្លារូបនីយកម្មជាផ្លូវការទេ ព្រោះម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា គេប្រមើលថា មានស្ថិរភាពល្អ និងមាននិន្នាការវិជ្ជមាន។ ផ្អែកលើបទពិសោធន៍ដែលបូលីវី និងប៉េរូ បានឆ្លងកាត់ មានការជួយមតិយ៉ាងខ្លាំងក្លាថា កម្ពុជាគួរជៀសវាងបដិដុល្លារូបនីយកម្មជាកាតព្វកិច្ច ពីព្រោះ វាអាចត្រឹមតែធ្វើឲ្យ ដុល្លារូបនីយកម្មកាន់តែកើនឡើង។ ក្នុងបញ្ហានេះ ការអភិវឌ្ឍទីផ្សារ អាចជាគោលនយោបាយដ៏ប្រសើរ សម្រាប់លើកកម្ពស់ប្រាក់រៀល (Tal and Dabadie 2007; Duma 2011)។ ការប្រៀបធៀបឆ្លងកាត់ប្រទេសនូវ បុរេលក្ខខណ្ឌសម្រាប់បដិដុល្លារូបនីយកម្មបានបង្ហាញនូវភាពមិនមិនស៊ីគ្នារវាងគោលនយោបាយលើកកម្ពស់ប្រាក់រៀល និង គោលនយោបាយទាក់ទាញលំហូរចូលមូលធនមកកម្ពុជា ពីព្រោះ កិច្ចប្រឹងប្រែងទាក់ទាញភ្ញៀវទេសចរ និងវិនិយោគិនបរទេស វាជាគ្រឿងលើកទឹកចិត្តឲ្យប្រើប្រាក់ដុល្លារ។

ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅអេក្វាទ័រ មិនខុសគ្នាអ្វីច្រើនពីនៅប៉េរូ និងបូលីវីទេ ប៉ុន្តែអេក្វាទ័រជាប់ចំណាត់ថ្នាក់ទី៦ នៅក្នុង Trading Economics (2016) ព្រោះមិនអាចចេញផ្សាយរូបិយវត្ថុក្នុងស្រុករបស់ខ្លួនបាន។ កត្តាមួយដែលចូលរួមចំណែកកាត់បន្ថយដុល្លារូបនីយកម្មក្នុងសេដ្ឋកិច្ចនៅបូលីវី និងប៉េរូ គឺការចេញផ្សាយប័ណ្ណរតនាគារជារូបិយវត្ថុក្នុងស្រុក។ ដោយស្ថិតនៅចំណាត់ថ្នាក់ទី៦ កម្ពុជាមានស្ថានភាពល្អ ដើម្បីចេញផ្សាយប័ណ្ណរតនាគារជាប្រាក់រៀល។ ការធ្វើដូច្នេះ អាចជួយជំរុញការប្រើប្រាស់ប្រាក់រៀល ហើយបង្កើនបំណុលក្នុងស្រុក ជាជាងបំណុលបរទេស។

ក្នុងចំណោមគោលនយោបាយប្រយ័ត្នប្រយែង បានអនុម័តប្រើដោយប្រទេសទាំងបី ដូចបានលើកយកមកសិក្សាប្រៀបធៀបនេះ គោលនយោបាយដែលហុចលទ្ធផលជាផ្លែផ្កាច្រើនជាងគេក្នុងការគ្រប់គ្រងដុល្លារូបនីយកម្ម មានបីសំខាន់ៗ គឺអត្រាប្រាក់បម្រុងកាតព្វកិច្ច ការបង្កើតសំវិធានធន សម្រាប់ហានិភ័យលើឥណទាន និងអន្តរាគមន៍លើអត្រាប្តូរប្រាក់។ បូលីវី និង ប៉េរូ បានកំណត់ឲ្យមានគម្លាតគ្នាយ៉ាងធំរវាង អត្រាប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណបរទេស និងជារូបិយវត្ថុក្នុងស្រុក ប៉ុន្តែកម្ពុជាកំណត់គម្លាតនេះ តូចណាស់ គឺ ៨% សម្រាប់ប្រាក់រៀល និង ១២,៥% សម្រាប់រូបិយប័ណ្ណបរទេស (NBC 2016)។ ប្រទេសដែលបានយកមកប្រៀបធៀបទាំងបី បានដាក់អនុវត្តនូវ គោលនយោបាយដែលផ្ដល់អត្ថប្រយោជន៍ដល់រូបិយវត្ថុក្នុងស្រុក ច្រើនជាងរូបិយប័ណ្ណបរទេស។ ប៉ុន្តែ គោលនយោបាយកម្ពុជាផ្ដល់លក្ខខណ្ឌសឹងតែប្រហាក់ប្រហែលគ្នា សម្រាប់ការប្រើប្រាក់រៀល និងប្រាក់ដុល្លារ។ គេឃើញមានការជំរុញឲ្យប្រើប្រាស់ប្រាក់រៀលដែរ ហើយបញ្ញើជាប្រាក់រៀល ទទួលបានអត្រាការប្រាក់ខ្ពស់ជាង ប៉ុន្តែ កម្ចីជាប្រាក់រៀល ត្រូវបានគិតការប្រាក់ខ្ពស់ជាងបន្តិចទៅវិញ បើប្រៀបធៀបនឹងកម្ចីជាប្រាក់ដុល្លារ (NBC 2013)។ ប្រទេសបូលីវីបានអនុវត្តយកពន្ធលើប្រតិបត្តិការជារូបិយប័ណ្ណបរទេស និងបានកំណត់ពីទំហំនៃសំណុំកម្ចីជារូបិយវត្ថុក្នុងស្រុក។ កម្ពុជានៅមិនទាន់មានអនុវត្តគោលនយោបាយនេះទេ។

## សេចក្តីសន្និដ្ឋាន

ដុល្លារូបនីយកម្មកម្រិតខ្ពស់យូរអង្វែង នៅកម្ពុជា បង្កឡើងជាចម្បងមកពី ភាពមិនស៊ីគ្នានៃគោលនយោបាយដែលបង្កើតឡើង សម្រាប់លើកកម្ពស់ប្រាក់រៀល និងទាក់ទាញលំហូរចូលមូលធន។ កម្ពុជា ពិបាកនឹងអនុវត្តតាមបទពិសោធន៍នៅប្រទេសបូលីវី និងប៉េរូ ព្រោះ NBC មានតិចជាងនូវឧបករណ៍ខាងគោលនយោបាយ ដែលខ្លួនអាចប្រើបាន ហើយគោលនយោបាយដែលមានស្រាប់ មិនបានលើកទឹកចិត្តគ្រប់គ្រាន់ សម្រាប់លើកកម្ពស់ ការប្រើប្រាស់ប្រាក់រៀលឲ្យបានទូលំទូលាយឡើយ។ ម្យ៉ាងទៀត ទីផ្សារមូលធននៅកម្ពុជានៅមិនទាន់រីកលូតលាស់ពេញលេញទេ។ ប្រសិនបើកម្ពុជាចង់រក្សាវិស័យម៉ាក្រូសេដ្ឋកិច្ច និង នយោបាយឲ្យនៅតែមានលក្ខណៈវិជ្ជមានទៅអនាគតនោះ កម្ពុជាត្រូវធ្វើការកែលំអទីផ្សារមូលធនរបស់ខ្លួន។ ចំណុចនេះ អាចសម្រេចបាន តាមរយៈការចេញផ្សាយប័ណ្ណរតនាគារ។ ម្យ៉ាងវិញទៀត ដើម្បីបង្កើតនូវការលើកទឹកចិត្តឲ្យគេចង់ប្រើប្រាស់ប្រាក់រៀល គួរមានគោលនយោបាយប្រយ័ត្នប្រយែងច្រើនថែមទៀត និងសមស្របតាមស្ថានភាពទីផ្សារ និងគួរកាត់បន្ថយភាពមិនស៊ីគ្នាផ្នែកគោលនយោបាយឲ្យមកនៅកម្រិតទាបបំផុត។

## ឯកសារយោង

Alvarez-Plata, P., and A. García-Herrero. 2007. "To Dollarize or De-dollarize: Consequences for Monetary Policy." Manila: Asian Development Bank.

Beresford, Melanie, Nguon Sokha, Rathin Roy, Sau Sisovanna and Ceema Namazie**.** 2004. *The Macroeconomics of Poverty Reduction in Cambodia.* Phnom Penh: UNDP.

Catacora, Luis Alberto Arce. 2014. "The Model that Changed Bolivia's Economy." PowerPoint presentation at Harvard University, 5 September.

Duma, Nombulelo. 2011. *Dollarization in Cambodia: Causes and Policy Implications*. Working Paper 11/49. Washington: International Monetary Fund.

García-Escribano, Mercedes. 2010. *Peru: Drivers of De-dollarization*. Working Paper 10/169. Washington: International Monetary Fund.

García-Escribano, Mercedes, and Sebastian Sosa. 2011. *What is Driving Financial De-dollarization in Latin America?* Working Paper 11/10. Washington: International Monetary Fund.

Irvin, George. 1993. *Rebuilding Cambodia's Economy: UNTAC and Beyond.* Working Paper No. 149. The Hague: Institute of Social Studies.

Kang, K. 2005. " Is Dollarization Good for Cambodia?" *Global Economic Review* 34(2): 201-211.

Khorn Dalin. 2015. "The Obstacles to Promoting Local Currency: A Cross-Country Study of Bolivia, Ecuador and Peru", Master's thesis, Korea Development Institute School of Public Policy and Management.

Khou Vouthy and Ken Odajima. 2015. *Dollarization or Dedollarization? Dollarization in Cambodia Policy to Promote the Usage of Riel*. Phnom Penh: National Bank of Cambodia and JICA Research Institute.

McGrath, Cam 2015. "Central Bank Seeks To Promote Riel Use." *Khmer Times*, 1 July.

Menon, Jayant. 2008. "Cambodia's Persistent Dollarization: Causes and Policy Options."*ASEAN Economic Bulletin* 25(2): 228-237.

MEPF (Ministry of Economy and Public Finance). 2013. *Memoria De La Economía Boliviana 2013.* Phnom Penh: Ministry of Economy and Public Finance.

NBC (National Bank of Cambodia). 2005. *Annual Report 2005.* Phnom Penh: National Bank of Cambodia.

NBC. 2010. *Annual Report 2010.* Phnom Penh: National Bank of Cambodia.

NBC. 2013. *Annual Report 2013.* Phnom Penh: National Bank of Cambodia.

NBC. 2014. *2014 Annual Report: General Directorate of Banking Supervision.* Phnom Penh: National Bank of Cambodia.

NBC.2016. "Reserve Requirements." Accessed 2 Feb 2016, http://nbc.org.kh/english/monetary_ policy/reserve_ requirements.php.

Prasso, S.T. 2001. "The Riel Value of Money: How the World's Only Attempt to Abolish Money Has Hindered Cambodia's Economic Development." *AsiaPacific Issues No. 49*. Honolulu: East-West Center.

Rossini, Renzo, Zenon Quispe and Enrique Serrano. 2013. *Foreign Exchange Intervention in Peru.* BIS Papers No 73. Accessed 26 Apr 2016, http://www.bis.org/publ/bppdf/ bispap 73r.pdf.

Staines, N. 2014. "De-Dollarization: A Cross-Country Perspective." Washington: International Monetary Fund.

Tal Nay Im and Michael Dabadie. 2007. "Dollarization in Cambodia." Phnom Penh: National Bank of Cambodia.

Trading Economics. 2016. "Credit Rating." Accessed 3 Oct 2015, www.tradingeconomics.com/ country-list/rating.

World Bank. 2015. "Maintaining High Growth: Cambodia Economic Update". Phnom Penh: World Bank.

World Bank. 2016. "World Development Indicators 2015." Accessed 26 Apr 2016, http://data.worldbank.org/country/ cambodia.

WTTC (World Travel and Tourism Council). 2015. "Travel and Tourism: Economic Impact 2015 Cambodia." London: World Travel and Tourism Council.